**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍**

លេខ : ១៤៤៩ ប៥. ថ្ងៃ ចន្ទ ៨កើត ខែបឋមាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ២០២៦

# សេចក្តីជូនដំណឹង
## ស្តីពី
## ការដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវ "ផតថលសម្រាប់អ្នកអភិវឌ្ឍសុសវែរ ដំណាក់កាលទី១ (Developer Portal -Phase I)"

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ (**ក.ប.ទ.**) សូមជម្រាបជូនដល់ **ឯកឧត្តម លោកជំទាវ លោក លោកស្រី** ជាថ្នាក់ដឹកនាំ មន្ត្រីរាជការ និងបុគ្គលិកទាំងអស់ ជ្រាបថា ដើម្បីចូលរួមចំណែកលើកកម្ពស់គុណភាព និងអន្តរប្រតិបត្តិការនៃការអភិវឌ្ឍសុសវែរ ព្រមទាំងឆ្លើយតបទៅនឹងសកម្មភាពអាទិភាពនៃក្របខណ្ឌយុទ្ធសាស្ត្រទី៣០ នៃគោលនយោបាយរដ្ឋាភិបាលឌីជីថលឆ្នាំ២០២២-២០៣៥ **ក.ប.ទ.** សម្រេចដាក់ចេញ **"ផតថលសម្រាប់អ្នកអភិវឌ្ឍសុសវែរ ដំណាក់កាលទី១ (Developer Portal – Phase I)"** សម្រាប់អនុវត្តក្នុងក្របខណ្ឌ **ក.ប.ទ.** ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ។

ផតថលនេះនឹងដើរតួជាច្រករួមតែមួយ (one single service) ដែលនឹងផ្តល់នូវគោលការណ៍ណែនាំរួមនៃការអភិវឌ្ឍសុសវែររបស់អ្នកអភិវឌ្ឍសុសវែរទូទៅ ទាំងក្នុងរដ្ឋាភិបាល និងវិស័យឯកជន។ ផតថលនេះត្រូវបានអភិវឌ្ឍឡើងដោយអ្នកជំនាញរបស់ **ក.ប.ទ.** និងបានពិភាក្សាផ្ទៃក្នុងជាមួយអង្គភាពពាក់ព័ន្ធ ដោយចែកចេញជា ៣ ផ្នែកធំៗ រួមមាន (១)មគ្គុទ្ទេសក៍ក្នុងការអភិវឌ្ឍសុសវែរ (វដ្តនៃការអភិវឌ្ឍសុសវែរ គោលការណ៍នៃការគ្រប់គ្រងទិន្នន័យអ្នកប្រើប្រាស់ អន្តរប្រតិបត្តិការ និងសន្តិសុខសាយប័រជាដើម) (២)លំនាំបែបបទសរសេរកូដ និង(៣)ការតាំងបង្ហាញផលិតផលរដ្ឋាភិបាលឌីជីថល។

អាស្រ័យហេតុនេះ សូម **ឯកឧត្តម លោកជំទាវ លោក លោកស្រី** មេត្តាចូលរួមគាំទ្រ សិក្សាស្វែងយល់ និងអនុវត្តតាមគោលការណ៍ណែនាំ ប្រកបដោយស្មារតីទទួលខុសត្រូវ ដើម្បីពង្រឹងប្រព័ន្ធរបស់ក្រសួងឱ្យកាន់តែមានគុណភាព សុវត្ថិភាព និងមានកម្រិតអន្តរប្រតិបត្តិការល្អ ក្នុងគោលដៅកសាងរដ្ឋាភិបាលឌីជីថលប្រកបដោយទំនុកចិត្ត និងប្រសិទ្ធភាពខ្ពស់។/.

**សូមស្កេន QR Code ឬចូលតាមរយៈតំណភ្ជាប់**
**go.gov.kh/mptc/devgovkh ដើម្បីចូលទៅកាន់ផតថល**

GO.gov.KH

អគារលេខ ១៣ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក
ខណ្ឌដូនពេញ រាជធានីភ្នំពេញ 120210

123 023 724 810
www.mptc.gov.kh